# ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម សិក្ខាសាលាពិគ្រោះយោបល់រវាងអ្នកផលិត អ្នកផ្គត់ផ្គង់ផលលិតផលខ្មែរ



**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានថ្លែងបញ្ជាក់ថា ខ្មែរត្រូវមានមោទនភាព ចំពោះផលិតផលរបស់ខ្លួន និងជួយគាំទ្រផលិតផលយើង ហើយលោកសាទរ បើមានអ្នកវិនិយោគណា ដែលបង្កើតផ្សារផលិតផលខ្មែរសុទ្ធ ពីព្រោះមានសក្តានុពលណាស់ ស្របពេលទេសចរណ៍ បរទេសមកកម្ពុជា ក្នុងមួយឆ្នាំៗ ពី៤ ទៅ៥ លាននាក់ ដែលពួកគេត្រូវការទិញផលិតផលក្នុងស្រុក ជាអនុស្សាវរីយ៍។





ការថ្លែងបែបនេះ គឺក្នុងឱកាសដែលលោកអញ្ជើញចូលរួម ក្នុងកម្មវិធី សិក្ខាសាលាពិគ្រោះយោបល់ រវាងអ្នកផលិត អ្នកផ្គត់ផ្គង់ផលលិតផលខ្មែរ ជាមួយអ្នកប្រើប្រាស់ និងអ្នកចែកចាយបន្ត ដែលមាន ក្រសួងពាក់ព័ន្ធ សំខាន់ៗចំនួន៤រួមមាន ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងពាណិជ្ជកម្ម, ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និងក្រសួងទេសចរណ៍ នាព្រឹកថ្ងៃទី១៧ ខែសីហា ឆ្នាំ ២០១៧ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានថ្លែងក្នុងន័យឆ្លើយតប នឹងកង្វល់របស់អាជីករ សិប្បករ ក៏ដូចជាអ្នកចែកចាយ និងអ្នកផលិត ទាក់ទងនឹងបញ្ហាមួយចំនួន ដូចជាបញ្ហាទីផ្សារ-ការប្រកួតប្រជែង និងយុទ្ធនាការទិញផលិតផលខ្មែរជាដើមនោះ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានលើកឡើង ពីនិន្នាការរីកចម្រើននៃសេដ្ឋកិច្ចសកលលោក និងភាពប្រកួតប្រជែងស្រួចស្រាវ នៃទីផ្សារអន្តរជាតិ។

ជាក់ស្តែងគ្រាន់តែបរិបទ នៃសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលមានប្រទេសអាស៊ាន ១០ ជាសមាជិក ការប្រកួតក្នុងតំបន់មួយនេះ មានលក្ខណៈស្រួចស្រាវទៅហើយ ពីព្រោះ ដោយសារវាមានលំហូរសេរី នូវទំនិញ សេវា មូលធន និងកំលាំងពលកម្មជាដើម។ ដូច្នេះសហគ្រាស ក៏ដូចជាឧស្សាហកម្ម ក្នុងស្រុករបស់យើង ត្រូវតែពង្រឹង និងកែច្នៃសង្វាក់ផលិតរបស់ខ្លួន ធ្វើយ៉ាងណាឲ្យផលិតផល ឬទំនិញ

របស់យើងផលិតចេញមក មានគុណភាព ការវេចខ្ចប់ប្រកប ដោយសោភ័ណ្ឌភាព មានស្តង់ដារ និងតម្លៃសមរម្យ ផងដែរ។



ចំណុចនេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានបញ្ជាក់ថា កន្លងមក កម្ពុជា ក្នុងនាមជាប្រទេសអភិវឌ្ឍន៍តិចតួច និងការខិតខំក្នុងការធ្វើសមាហរណកម្ម របស់ខ្លួនក្នុងតំបន់ និងពិភពលោក កម្ពុជាមានសក្តានុពលខ្លាំងណាស់ តាមរយៈការទទួលបានភាព អនុគ្រោះពាណិជ្ជកម្ម ដែលអាចនាំទំនិញទៅក្រៅប្រទេសជាច្រើន ដោយមិនជាប់ពន្ធ និងកូតានាំចេញ។ ប៉ុន្តែយើងគួរស្វែងយល់ថា កត្តានេះយើងគ្រាន់តែ បានឆ្លងកាត់ដំណាក់កាលរបាំងពន្ធប៉ុណ្ណោះ។ ក្នុងនោះដើម្បីមានឧត្តមភាព ប្រកួតប្រជែង យើងត្រូវជំនះរបាំងមួយទៀត គឺរបាំងមិនមែនពន្ធគយ ឬហៅថារបាំងបច្ចេកទេស ដែលទាក់ទងជាសំខាន់ទៅលើកត្តាអនាម័យ និងភូតគាមអនាម័យ (SPS) និងបទដ្ឋានស្តង់ដារ ជាដើម។

ទាក់ទងការងារនេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានលើកឡើងពីការខិតខំ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលលោក ក្នុងនាមជាប្រធានក្រុមប្រឹក្សាស្តង់ដារជាតិ បានជម្រុញឲ្យមានការខិតខំ យកស្តង់ដារម្ហូបអាហារ និងស្តង់ដារផលិតផលអន្តរជាតិ ក៏ដូចជាស្តង់ដារអាស៊ាន មកធ្វើជាស្តង់ដារជាតិ បានចំនួន ៨០៤ ស្តង់ដាររួចហើយ ដើម្បីឲ្យការផលិតទំនិញនៅកម្ពុជា អាចនាំចេញបាន ដោយមិនជាប់របាំងបច្ចេកទេស។ ទាក់ទងការបន្លំឈ្មោះប្រទេសអ្នកផលិត លោកទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា

បើផលិតករ សិប្បករ ឬឧស្សាហករ ចង់រក្សាផលិតផលរបស់ខ្លួនថា ពិតជាផលិតនៅកម្ពុជាពិត ប្រាកដ ត្រូវបំពេញលក្ខខ័ណ្ឌ តម្រូវមួយចំនួនដូចជា ក្រុមហ៊ុន រោងចក្រ ឬសហគ្រាសត្រូវចុះបញ្ជី នៅក្រសួងពាណិជ្ជកម្ម ឬក្រសួងឧស្សាហកម្ម និងសិប្បកម្ម-សុំវិញ្ញាបនបត្រដំណើរការ និងបន្ទាប់មកត្រូវចុះបញ្ជីផលិតផល នៅវិទ្យាស្ថានស្តង់ដារកម្ពុជា ឬបិទ Bar Code ដើម្បីបញ្ជាក់ថា ផលិតផលនោះបានផលិតនៅកម្ពុជា ពិតប្រាកដ។

ទាក់ទងនឹងផលិតផល និងទីផ្សារសូត្រ លោកបានអំពាវនាវឲ្យអ្នកផលិតផលិតផលចេញពីសូត្រ យកគំរូស្នាដៃរបស់ខ្លួនមកចុះបញ្ជីការពារ និងទទួលស្គាល់ គំនូរឧស្សាហកម្មរបស់ខ្លួន នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយក្រសួងមិនគិតតម្លៃសេវាឡើយ។ ទាក់ទងនឹងយុទ្ធនាការ ទិញផលិតផលខ្មែរ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានបញ្ជាក់ថា ខ្មែរត្រូវមានមោទនភាព ចំពោះផលិតផលរបស់ខ្លួន និងជួយគាំទ្រផលិតផលយើង ហើយលោកសាទរ បើមានអ្នកវិនិយោគណា ដែលបង្កើតផ្សារផលិតផលខ្មែរសុទ្ធ ពីព្រោះមានសក្តានុពលណាស់ ស្របពេលទេសចរណ៍បរទេសមកកម្ពុជា ក្នុងមួយឆ្នាំៗ ពី៤ ទៅ៥ លាននាក់ ដែលពួកគេត្រូវការទិញផលិតផលក្នុងស្រុក ជាអនុស្សាវរីយ៍។

ជាការឆ្លើយ នឹងសំណួរទាក់ទង នឹងគំហុកនៃទំនិញក្រៅស្រុក ចូលលុកលុយទីផ្សារកម្ពុជា ទាំងទីផ្សារទំនើប និងទីផ្សារធម្មតា លោកបានបញ្ជាក់ថា ទីផ្សារសេរី យើងមិនអាចទប់ស្កាត់គេបានទេ។ យើងត្រូវអភិវឌ្ឍន៍ផលិតផលរបស់យើង ឲ្យស្របតាមស្តង់ដារ មានគុណភាពខ្ពស់ សោភ័ណ្ឌភាព និងតម្លៃអាចទទួលយកបាន។ បន្ទាប់មក **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** និងគណៈអធិបតី ដែលក្នុងនោះរួមមាន **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** និង **ឯកឧត្តមតំណាងក្រសួងទេសចរណ៍** បានអញ្ជើញជាសាក្សីភាពក្នុងពិធិចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា រវាងភាគីអ្នកផលិតផ្គត់ផ្គង់ និងអ្នកចែកចាយ។


រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧


រវាង
អ្នកផលិត និងអ្នកផ្គត់ផ្គង់ផលិតផលខ្មែរ
ជាមួយ
អ្នកប្រើប្រាស់ និងអ្នកចែកចាយបន្ត
រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧


រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧